# ការចូលរបស់ពលរដ្ឋ



# យល់ដឹងពីសង្គមស៊ីវិល

- ចាប់កំណើតក្នុងមស្ទឹមប្រទេស នាសតវត្សរ៍ទី ១៧ ។

- ទស្សនទាន "**សង្គមស៊ីវិល**" ត្រូវបានគេឱ្យនិយមន័យ និង ការយល់ឃើញខុសៗគ្នាពីជំនាន់មួយទៅជំនាន់មួយ។

- ការចាប់អារម្មណ៍លើសង្គមស៊ីវិលចាប់ផ្តើមផុសផុលឡើង ក្រោយការដួលរលំនៃរបបកុម្មុយនិស្តនៅអឺរ៉ុបខាងកើតនិងកណ្តាល។

- ទស្សនទាននិងប្រតិបត្តិការនាទសវត្សរ៍កន្លងមក ចាប់ផ្តើមមានសារសំខាន់ក្នុងអំឡុងពេលមានការផ្លាស់ប្តូរតួនាទីដ៏ចម្បងរបស់រដ្ឋនិងសេដ្ឋកិច្ចទីផ្សារ។

# យល់ដឹងពីសង្គមស៊ីវិល -ត-

- **ការយល់ឃើញលើកដំបូង** កើតចេញពីប្រពៃណីអង់គ្លេ-អាមេរិកាំង និងស្នាដៃរបស់សង្គមវិទូ Tocqueville។ សង្គមស៊ីវិលត្រូវបានគេមើលឃើញថា ជាអន្តរការីនៅចន្លោះបុគ្គលនិងគ្រួសារ ឬម្យ៉ាងវិញទៀតរវាងបុគ្គល និងស្ថាប័នរដ្ឋ ។
- **អត្ថន័យទីពីរ** សង្គមស៊ីវិល កើតចេញពីការប្រឈមមុខរវាងប្រជាពលរដ្ឋ និងរបបកុម្មុយនីស្ត នៅអឺរ៉ុបខាងកើត។
- **ការយល់ឃើញទីបី** មានឫសគល់ចេញពីការទទួលយកទីផ្សារសេរីជាសកល និងសហគ្រាសឯកជន ជាម៉ាស៊ីនអភិវឌ្ឍសេដ្ឋកិច្ច ។

សង្គមស៊ីវិលជាច្រើនបានជួយអង្គភាពដទៃធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាពតាមរយៈផ្តល់ការគាំទ្រ ដូចជា មូលនិធិសប្បុរសធម៌ សមាជិក និងបណ្តាញអង្គភាព។ល។ អង្គការអន្តរការីទាំងនេះក៏ស្ថិតក្នុងអត្ថន័យដ៏ទូលំទូលាយរបស់សង្គមស៊ីវិលដែរ។

# ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ

**ការរៀបចំឯកសារព័ត៌មាន សំរាប់ប្រជាសមូហភាព**

-ធ្វើផែនទីអំពីអង្គការមូលដ្ឋាន
-រកអ្នកដឹកនាំមានសក្តានុពល
-រកពលរដ្ឋសកម្ម។

**ការបណ្តុះបណ្តាលសំរាប់ប្រជាសមូហភាពនិងពលរដ្ឋផងបង្គោល**

បណ្តុះបណ្តាលខ្លីៗជាស៊េរីអំពីអភិបាលកិច្ចថ្នាក់មូលដ្ឋាន និងភាពជាពលរដ្ឋ។

**ការប្រជុំជាទៀងទាត់ និងការគាំទ្រដំណើរការ**

ដើម្បីគាំទ្រដំណើរការចំពោះសមូហភាព
និងការដឹកនាំប្រជាសមូហភាព

**ទស្សនកិច្ចសិក្សា**

ដើម្បីអ្នកដឹកនាំមើលឃើញគំនិតផ្តួចផ្តើម អភិ.វដែលអាចចម្លងយកបាន

**សិក្ខាសាលា/កិច្ចប្រជុំផ្ទាល់ជាមួយប្រជាពលរដ្ឋ**

ដើម្បីជំរុញទំនាក់ទំនងដ៏មានប្រសិទ្ធភាពរវាងប្រ/ពនិងស្ថាប័ននានា។

**ការរៀបចំយុទ្ធនាការ**

កិច្ចខិតខំធ្វើឡើងដើម្បីកសាងភាពជាម្ចាស់ តាមរយៈការបង្កឱ្យប្រ/ពជាប់ពាក់ព័ន្ធ និងការដឹកនាំក្រុមចាប់ពីការធ្វើផែនការដល់ការអនុវត្តន៍យុទ្ធនាការ។

**ការសំរួលបណ្តាញនៃប្រជាសមូហភាព**

ការសំរួល និងជំរុញបណ្តាញនៃប្រជាសមូហភាពដោយផ្តោតសំខាន់លើស្ត្រី ជនភាគតិច និងក្រុមជនងាយរងគ្រោះនានា។

# ភាពជាពលរដ្ឋ

- ពាក្យថា **"ភាពជាពលរដ្ឋ"** ត្រូវបានពិភាក្សា កំណត់អត្ថន័យ និងយល់ឃើញខុសៗពីគ្នា
- នៅក្នុងបរិបទបច្ចុប្បន្នប្រទេសភាពជាពលរដ្ឋសំដៅលើជំរើសបុគ្គល។
- គេចាត់ទុកថា សកម្មភាពបុគ្គល "ប្រកបដោយហេតុផល" ដើម្បីបង្កើនផលប្រយោជន៍របស់គេនៅក្នុងសង្គម។
- ការផ្តោត ជាសំខាន់លើជំរើសរបស់បុគ្គល គឺផ្អែកលើសច្ចភាពដែលរដ្ឋនឹងផ្តល់ឱ្យនូវការការពារជាចាំបាច់ ហើយនឹងអនុញ្ញាតក្នុងការប្រើប្រាស់ជរើសទាំងនេះរបស់បុគ្គល។
- មយ៉ាងវិញទៀតមិនត្រូវទទួលស្គាល់ថាជំរើសរបស់ បុគ្គលត្រូវបានដាក់លក្ខណ្ឌកំរិតដោយវិសមភាពនៅក្នុងសង្គមនោះទេ។

# ភាពជាពលរដ្ឋ -គ-

## ស្នូលនៃភាពជាពលរដ្ឋ

**សិទ្ធិ**

ភាពជាពលរដ្ឋដែលជា "**សិទ្ធិ**" ជាស្ថានភាពផ្លូវការដែលអនុញ្ញាតិដោយរដ្ឋ។ បុគ្គលត្រូវទទួលបានសិទ្ធិជាក់លាក់ជាសកលដែលដាក់តំកល់នៅក្នុងច្បាប់។

និង

**កាតព្វកិច្ច**

ភាពជាពលរដ្ឋដែលជា "**កាតព្វកិច្ច**" ជាការចូលរួមដែលមានចរិតនយោបាយនៃប្រជាពលរដ្ឋទាំងអស់ដែលជា កាតព្វកិច្ច។

# យែនឌ័រ និងអភិបាលកិច្ច

ទាំងស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាស្ថិតក្រោមច្បាប់ មានឱកាសស្មើគ្នា រួមទាំងភាពស្មើគ្នាក្នុងការទទួលបានសមត្ថភាព និងធនធានផលិតផលផ្សេងៗទៀតដែល ជួយឱ្យមាន ឱកាសនិងភាពស្មើគ្នាក្នុងការបញ្ចេញសម្លេងដើម្បីជាប្រយោជន៍ និងចូលរួមចំណែកដល់ដំណើរការអភិវឌ្ឍ។

(ធនាគារពិភពលោក: ២០០១)។

ការចូលរួមស្មើៗគ្នារបស់បុរសនិងស្ត្រីក្នុងការគ្រប់គ្រង គឺមានសារៈសំខាន់ខ្លាំងណាស់ ចំពោះហេតុផលមួយចំនួនដូចខាងក្រោម :

- មានឥទ្ធិពលលើការបែងចែកធនធានកម្រ
- លើកកម្ពស់ល័ក្ខខ័ណ្ឌរស់នៅ និងបង្កើនចំណាប់អារម្មណ៍របស់ស្ត្រី
- ផ្លាស់ប្តូរការផ្តោតកិច្ចការនយោបាយតបទៅតាមបញ្ហានានាដែលជះឥទ្ធិពលដល់គុណភាពនៃការរស់នៅ។

# សូមអរគុណ !

